**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តក្រចេះ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៦៦០
ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨
ជំនុំជម្រះលេខ ៥៩
ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌ
លេខ ១២១ "ឥ"
ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

# <u>តាងនាមប្រជារាស្ត្រខ្មែរ</u>
# <u>សាលាដំបូងខេត្តក្រចេះ</u>

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ វេលាម៉ោងដប់ប្រាំមួយ និងសូន្យនាទី រសៀល ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តក្រចេះ

**<u>តំណាងអយ្យការ</u>**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តក្រចេះ

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ

**<u>ដើម្បីជំនុំជម្រះ</u>**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៦៦០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តក្រចេះ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] **សារ៉ុន (ពៅ)** ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] **ខៅ** "ស្លាប់" ម្ដាយឈ្មោះ [redacted] **ឡុង** "ស្លាប់" ប្រពន្ធឈ្មោះ [redacted] ចាន់ មានកូន០៥នាក់ ជានីតិជនទោសពីមុខ **គ្មាន** ។(ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ហិង្សាដោយចេតនា(ស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ)** តាមមាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

-លោកមេធាវី [redacted] ជាមេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] តឿ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **តឿ** ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូមិត្រពាំងឬស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេតកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] សន "ស្លាប់" ម្ដាយឈ្មោះ [redacted] សែ "ស្លាប់" មានប្រពន្ធឈ្មោះ [redacted] លន់ មានកូន០៧នាក់ ។

-**បានឃើញ** ពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] តឿ ភេទប្រុស អាយុ៥២ឆ្នាំ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅអយ្យការអមសាលាដំបូងខេត្តក្រចេះ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ៩៩៨ អ.យ.ក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តក្រចេះ ។



Scanned with CamScanner

រឿងនេះខ្លួនសូមទាមទារសំណងជម្ងឺចិត្តចំនួន ៣០០០$ (បីពាន់ដុល្លារអាមេរិក) ដោយសារខ្លួននៅជំពាក់លុយគេ ហើយខ្លួនពុំបានចេញទៅរកស៊ីអ្វីទេ ដោយសារខ្លាចឈ្មោះ ពៅ តាមធ្វើបាប ។ នៅថ្ងៃនោះខ្លួនពុំបានរករឿងគេមុនទេ និងពុំបាននិយាយសួរអ្វីទៅកាន់ឈ្មោះ [redacted] សារុន ទេ នៅពេលនោះអត់មានឈ្លោះគ្នាទេ និងពុំបានវៃគ្នាទេ ។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយឈ្មោះ [redacted] សារុន នៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ០៨យប់ ខ្លួនបានដើរផ្ទុះសត្វកង្កែបជាមួយក្មេងប្រុសម្នាក់ឈ្មោះ[redacted] យី ភេទប្រុស អាយុ១២ឆ្នាំ សញ្ជាតិខ្មែរ រស់នៅភូមិអូរកណ្ដៀរ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ។ ពេលនោះពួកខ្លួនបានដើរផ្ទុះសត្វកង្កែបនៅចំណុចត្រពាំងឈូក ដែលមានទីតាំងស្ថិតនៅភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ដោយខ្លួនមាន កាន់ស្នារសម្រាប់បាញ់សត្វ ចំនួន០១ កូនកាំបិត ចំនួន០១ និងមានពិលសម្រាប់ផ្ទុះសត្វ ចំនួន០២(ខ្ញុំកាន់ពិល ចំនួន០១ និងឈ្មោះ [redacted] យី កាន់ពិល ចំនួន០១ដែរ) ។ ខណៈពេលដែលពួកខ្លួនកំពុងតែផ្ទុះសត្វកង្កែប ស្រាប់តែមានឈ្មោះ [redacted] តឿ អង្គុយនៅគុម្ពព្រៃក្បែរនោះបានស្រែកហៅពួកខ្លួនថា ពួកអែងមកនេះមើល! រួចពួកខ្លួនក៏នាំគ្នាដើរទៅ បន្ទាប់មកទៀតឈ្មោះ [redacted] តឿ បានសួរខ្លួនថា អែងឈ្មោះអី? ហើយខ្ញុំឆ្លើយថា ខ្ញុំឈ្មោះ ពៅ ហើយ លោកឯងមានការអី? ពេលនោះឈ្មោះ [redacted] តឿ បានឆ្លើយថា បើអាពៅដាក់ខ្នោះឱ្យហើយ ពួកអ្អែងមកដាក់ខ្នោះអាពៅ (ពេលនោះឈ្មោះ [redacted] តឿ បានស្រែកហៅកូនចំនួន ០២នាក់ដែលខ្ញុំមិនបានស្គាល់ឈ្មោះឲ្យមកចាប់ខ្ញុំដាក់ខ្នោះ) ។ បន្ទាប់មកទៀតឈ្មោះ [redacted] តឿ បានស្ទុះមកចាប់កាំបិតដែល ខ្លួនបានកាន់ជាប់នឹងដៃស្តាំរបស់ខ្លួន ពេលនោះខ្លួនបានប្រាប់ [redacted] តឿ ឱ្យលែងកាំបិតរបស់ខ្លួន ប៉ុន្តែ ឈ្មោះ [redacted] តឿ ពុំព្រមលែងឡើយ ទើបខ្លួនទាញកន្ត្រាក់ចេញមកបណ្ដាលឱ្យផ្តែកាំបិតមុតដៃឈ្មោះ [redacted] តឿ ចេញឈាមតែម្តង ។ ក្រោយមកខ្លួន និងឈ្មោះ [redacted] យី បាននាំគ្នាដើរត្រលប់មកផ្ទះវិញ ពេលនោះឈ្មោះ [redacted] តឿ និងកូនចំនួន ០២នាក់ទៀត ប្រដាប់ដោយដំបងបានដើរតាមពួកខ្លួនពីក្រោយរហូត និងស្រែកថា អ្អែងឈប់មើលអញអ្អែងឱ្យងាប់ ! ប៉ុន្តែពួកខ្លួនមិនបានឈប់ឡើយដោយនាំគ្នាដើររហូតដល់ផ្ទះ រួចខ្លួនបានយកទូរសព្ទគេរាយការណ៍ទៅប៉ូលីស ទើបឈ្មោះ [redacted] តឿ និងបក្សពួកនាំគ្នាត្រលប់ទៅវិញ ។ ខ្លួនពុំមានលទ្ធភាពសងសំណងឱ្យដើមបណ្តឹងទេ សំណូមពរសុំតុលាការជួយរកយុត្តិធម៌ និងសុំបញ្ចប់រឿង ខ្លួនសូមសន្យាមិនឱ្យមានគុំគួនរវាងរូបខ្លួន ក៏ដូចជាឈ្មោះ [redacted] តឿ និងខ្លួនមិនប្រព្រឹត្តអំពើខុសច្បាប់ឡើយ ។

ក្រឡាបញ្ជីអានកំណត់ហេតុសាក្សីឈ្មោះ [redacted] យី នៅដំណាក់កាលអយ្យការបានឆ្លើយថា៖ កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ០៨យប់ ខ្លួនកំពុងតែដើរផ្ទុះ សត្វជាមួយពូខ្លួនឈ្មោះ ពៅ នៅចំណុចត្រពាំងឈូក ដែលមានទីតាំងស្ថិតនៅភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ស្រាប់តែឈ្មោះ តឿ ដើរមកដល់បានសួរពួកខ្លួនថា អ្នកណាឱ្យដើរផ្ទុះសត្វនឹង? ពេលនោះពូខ្លួនឈ្មោះ ពៅ ក៏បានប្រាប់ទៅវិញថា ដើរផ្ទុះសត្វចាំបាច់ប្រាប់លោកឯងដែរ! បន្ទាប់មកទៀតពូខ្លួនឈ្មោះ ពៅ និងឈ្មោះ តឿ ក៏បានវៃគ្នាទៅវិញទៅមក។ ក្រោយមកឈ្មោះ តឿ បានស្រែកហៅកូនគាត់ចំនួន ០២នាក់ទៀតឱ្យមកជួយវៃពូខ្លួនឈ្មោះ ពៅ ពេលនោះពូខ្លួនឈ្មោះ ពៅ បានប្រាប់ខ្លួនថា អាយីយកកាំបិតឱ្យអញ! អញចាក់អានឹងម្តង ! រួចពូខ្លួនឈ្មោះ ពៅ បានយកកូនកាំបិតពីខ្ញុំបម្រុងនឹងចាក់ឈ្មោះ តឿ ចំកណ្ដាលទ្រូង ស្រាប់តែឈ្មោះ តឿ ស្ទុះមកចាប់កាំបិតជាប់រួចពូខ្លួនឈ្មោះ ពៅ ទាញកាំបិតយកទៅវិញបណ្ដាលឱ្យមុតដៃរបស់ឈ្មោះ តឿ តែម្តង ។



Scanned with CamScanner

ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១. កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង៨យប់ នៅចំណុចត្រពាំងឈូក ភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ មានករណី **ហិង្សាដោយចេតនា (ស្ថានទម្ងន់ទោសដោយការប្រើប្រាស់អាវុធ)** ប្រព្រឹត្តដោយបង្កទៅលើជនរងគ្រោះឈ្មោះ [redacted] **តឿ** ភេទប្រុស អាយុ៥២ឆ្នាំ បង្កដោយឈ្មោះ [redacted] សារ៉ុន ហៅ ពៅ ពិតប្រាកដមែន ។

២. ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, អំណានចម្លើយរបស់សាក្សី និងអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សារ៉ុន(ពៅ)** នាពេលសវនាការមានភាពស៊ីសង្វាក់គ្នា ដែលអាចឱ្យជឿបានថា ជនជាប់ចោទគឺពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ពិតប្រាកដមែន ។

៣. ជនជាប់ចោទមានកម្រិតអាយុអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។

៤. ជនជាប់ចោទប្រាកដជាយល់ដឹងច្បាស់ថា ខ្លួនពុំត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដូចការចោទប្រកាន់ខាងលើនោះទេ ប៉ុន្តែខ្លួននៅតែប្រព្រឹត្តដោយចេតនាទុច្ចរិតដែលច្បាប់បញ្ញត្តិថាជាបទល្មើស និងផ្តន្ទាទោស ។

៥. អំពើរបស់ជនជាប់ចោទបានប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ។

៦.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

៧. មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សារ៉ុន (ពៅ) ភេទប្រុស អាយុ ៥៨ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **ហិង្សាដោយចេតនា(ស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ)** តាមមាត្រា២១៨ ចំណុច២ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិអូរព្រះ ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

៨. មេធាវី [redacted] បានសន្និដ្ឋានស្នើរសូមតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ និងសូមតុលាការសម្រេចផ្តល់សំណងជម្ងឺចិត្តមកកូនក្តីរបស់ខ្ញុំបាទ ចំនួន៣០០០$ (បីពាន់ដុល្លារអាមេរិក) ដូចការទាមទារកន្លងមក ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញមកតុលាការនូវថ្លៃចំណាយការព្យាបាល ក៏ដូចជាការខាតបង់ផ្សេងៗដែលខ្លួនទទួលរងនោះទេ គប្បីតុលាការពិចារណាលើការស្នើសុំនេះ ។



Scanned with CamScanner